# រឿងមិត្តវិន្ទុក

(ទោសនៃការមិនដឹងគុណ)

មាន សេចក្តីតំណាលថា ក្នុងសាសនាកាលនៃព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាម កស្សបៈ មានសេដ្ឋីបុត្រម្នាក់ឈ្មោះមិត្តវិន្ទុក មានសម្បត្តិមានទ្រព្យ ៨០ កោដិនៅក្នុងក្រុងពារាណសី ជាបុគ្គលទ្រុស្តសីល ឯមាតាបិតាជាសោតាបន្នបុគ្គល ។ លុះចំណេរជាខាងក្រោយមកបិតារបស់មិត្តវិន្ទុកធ្វើមរណកាល ។

បុរសឈ្មោះវិន្ទុកនិយាយនឹងមាតាថា បពិត្រលោកម៉ែ ខ្ញុំនឹងធ្វើជំនួញដោយសំពៅ ។ មាតានិយាយថា នៃកូនអ្នកជាកូនតូចមួយ ទ្រព្យនៅក្នុងផ្ទះនេះមានច្រើនណាស់ សមុទ្រមានទុកនិងសំពៅច្រើនណាស់អ្នកកុំទៅឡើយ ។ បុរសឈ្មោះមិត្តវិន្ទុក និយាយថា ខ្ញុំទៅឥឡូវនេះ ម៉ែមិនអាចឃាត់ខ្ញុំទេ ទោះបីម្តាយចាប់ដៃបុរសនោះក៏បុរសនោះរលាស់ដៃម្តាយចេញឲ្យដួលហើយ លោតកន្លងម្តាយស្ទុះទៅកាន់សមុទ្រដោយសំពៅ ។ លុះដល់គំរប់៧ថ្ងៃសំពៅនោះក៏ នៅនឹងថ្កល់ឥតកំរើកព្រោះអាស្រ័យបុរសឈ្មោះមិត្តវន្ទុកជាអ្នក ធ្វើអំពើអាក្រក់ ។ ពួកអ្នកសំពៅកំពុងចែកស្លាកដោយគិតថា នៅក្នុងសំពៅនេះមុនជាមានមនុស្សកាឡកណ្ណី លុះមនុស្សទាំងអស់គ្នាដែលនៅក្នុងសំពៅនោះ ចាប់ស្លាកជាគំរប់ ៣ដង ស្លាកនោះនៅតែដល់បុរសឈ្មោះមិត្តវន្ទុក ។

ក្នុងកាលនោះមនុស្សទាំងឡាយ ធ្វើក្បូនចាប់បុរសឈ្មោះមិត្តវិន្ទុកបោះចោរទៅក្នុងសមុទ្រ ។ បុរសនោះអណ្តែតទៅតាមក្បូន ដល់កោះមួយឃើញនគរមួយមានមុខទ្វារបួនក្នុងកោះនោះ ។ បានឮថា កោះនោះជាកោះឧស្សទនរក ជាកន្លែងសំរាប់នៅរបស់កម្មសត្វនរកច្រើនគ្នា ។ ចំណែកខាងនគរនោះ ហាក់ដូចជានគរដែលគេសម្រាប់តាក់តែងដោយគ្រឿងអលង្ការសព្វយ៉ាង ប្រាកដដោយកម្លាំងកម្មគឺកិរិយាប្រហារមាតាដល់បុរសឈ្មោះមិត្តវិន្ទុក ៗ ចូលទៅគិតថា អញនឹងបានជាស្តេចក្នុងនគរនេះ ហើយឃើញសត្វមួយរូបដែលកងចក្កដ៏មុតវិលនៅលើក្បាលកំពុងខ្សឹប ខ្សូល ។ ខណៈនោះកងចក្កដ៏មុតលើក្បាលសត្វនរក ប្រាដកដូចជាផ្កាឈូក ចំណាងប្រកបដោយអង្គប្រាំលើដើមទ្រូងប្រាកដ ដូចជាគ្រឿងសម្រាប់បិទនូវទ្រូងឈាមដែលហូរចេញ អំពីសរីរប្រាកដដូចជាគេលាបស្រឡាបដោយខ្លឹមចន្ទន៍ សំឡេងយំខ្សឹបខ្សូលថាជាចំរៀង ដែលកើតឡើងដល់បុរសមិត្តវិន្ទុកហើយ

ក៏ចូលទៅរកសត្វនរកនិយាយថា ម្នាលបុរសដ៏ចំរើនផ្កាឈូកនេះអ្នកឯងពាក់យូរ ណាស់ហើយ ចូរឲ្យខ្ញុំពាក់ម្តង ។ សត្វនរកប្រាប់ថាម្នាលសំឡាញ់ នេះមិនមាន ផ្កាឈូកទេ នេះជាកងចក្ក ។ បុរសនោះពោលថាអ្នកឯងពោលដូចនេះមិនចង់ឲ្យ ខ្ញុំសោះ ។ សត្វនរកគិតថា កម្មរបស់អញអស់ហើយ បុរសនោះសម្លាប់នៅមាតា ដូចជាអញបានធ្វើយ៉ាងនេះ បើដូច្នេះអញនឹងឲ្យកងចក្កនេះដល់បុរសនោះហើយ ហៅមកថា នែអ្នកដ៏ចំរើនអ្នកចូលមកមកទទួលផ្កាឈូកនេះ ទើបបោះកងចក្ក នោះទៅលើក្បាលបុរសនោះ ។ កងចក្កនោះវិលហាក់បីដូចជាកិនអម្បែងក្បាល បុរសនោះ ក្នុងខណៈនោះបុរសមិត្តវិន្ទុកដឹងថា វត្ថុនេះជាកងចក្កដ៏មុតស្រួចផ្តល់ នូវសេចក្តីវេទនាស្រែកយំថា ចូរអ្នកយកកងចក្កដ៏មុតរបស់អ្នកវិញទៅ ។ ចំណែក ឯសត្វនរកក៏រត់បាត់ក្នុងពេលនោះទៅ ។ មិត្តវិន្ទុកសោយនូវសេចក្តីទុក្ខនៅក្នុង ឧស្សទនរក នោះអស់កាលដ៏យូរដោយវិបាកជាគ្រឿងហូរមកមិនដាច់នៃ អកុសលកម្ម គឺកិរិយាសម្លាប់មាតា កាលបើផលនោះអស់ហើយ ក៏ចោលកងចក្ក ទៅតាមយថាកម្មនោះឯង ។

សូមអស់លោកអ្នកអនុមោទនា !

ចប់